ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ សជណសរ

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦

### ១. សេចក្តីផ្តើម

មាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ដំណាក់កាលគឺ (១)- ដំណាក់កាលទី១: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនាដល់ខែឧសភា (២)- ដំណាក់កាលទី២: ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង (៣)- ដំណាក់កាលទី៣: ការអនុម័តថវិកា ពីខែតុលា ដល់ ខែធ្នូ។ សម្រាប់ដំណាក់កាលទី១នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដើម្បីឱ្យក្រសួង ស្ថាប័ននីមួយៗមានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ២០១៦។ ហេតុនេះសម្រាប់ជំហានបន្ទាប់នៃដំណាក់កាលទី១ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦នេះ ដើម្បីផ្តល់គោលការណ៍ណែនាំ និងមគ្គុទ្ទេសក៍បច្ចេកទេសសំខាន់ៗសម្រាប់ជាជំនួយដល់គ្រប់ក្រសួង ស្ថាប័នក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផែនការថវិការយៈពេលមធ្យមបីឆ្នាំរំកិលដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំក្នុងដំណាក់កាលដំបូងនៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយឡែកមួយទៀតស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

ផែនការយុទ្ធសាស្ត្រថវិកាក៏ជាឧបករណ៍ដ៏សំខាន់មួយសម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២)-បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣)-ជាមូលដ្ឋានសម្រាប់ពន្យល់និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤)-ធានានិរន្តរភាពនៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានដាក់ចេញ និង (៥)-ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ថវិកា និងការវិភាជថវិកាប្រចាំឆ្នាំ។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ ភាពច្បាស់លាស់នៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាព សូចនាករ និង គោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តថវិកា

ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣" និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ក្នុងន័យនេះ ក្រសួង ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិកាតែមួយ ដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមនិវាទក្រសួង ស្ថាប័ននោះ។

ទន្ទឹមនឹងនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាមិនអាចខ្វះបានឡើយដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពនិងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការរៀបចំនិងគ្រប់គ្រងថវិកា។ ក្នុងន័យនេះ *ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវរៀបចំក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពី នាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង* មានដំណើរការដោយសកម្មប្រកបដោយការទទួលខុសត្រូវ។ **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យធនធានទាំងអស់ ក៏ដូចជាសកម្មភាពការងារទាំងអស់របស់ក្រសួង ស្ថាប័នខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាឱ្យការរៀបចំថវិកាមានប្រសិទ្ធភាព (ចំណាយត្រូវការពិតប្រាកដ) និងមានតុល្យភាពក្នុងការរៀបចំថវិកាទៅតាមនិងរវាងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី/យុទ្ធសាស្ត្រអាទិភាព នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នដែលបានរៀបចំ។

ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០០៨ មកទល់នឹងពេលនេះការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជារួមត្រូវបានកែលម្អជាលំដាប់។ ទោះជាយ៉ាងនេះក្តី ការងារនេះនៅតែមិនទាន់បានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយទេ ជាពិសេសក្រសួង ស្ថាប័នចាំបាច់ត្រូវកែលម្អថែមទៀតនូវផែនការយុទ្ធសាស្ត្រថវិកាស្របទៅតាមស្មារតី និងលទ្ធផលនៃការរៀបចំថវិកាឆ្នាំ២០១៥កន្លងទៅ។ លើសពីនេះនៅពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងស្ថិតក្នុងដំណាក់កាលទី២ថ្មីនៃការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការត្រៀមចូលដំណាក់កាលទី៣គឺការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោ-បាយ និងស្របតាម "ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០" ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមធ្យោបាយ ឆ្ពោះទៅរកប្រព័ន្ធថវិកាថ្មីគឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវបានបង្កើនពីចំនួន១០ នៅឆ្នាំ២០១៥ ដល់ចំនួន២៥ នៅឆ្នាំ២០១៦ រួមមាន÷

- ក្រសួងចំនួន១០ អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ក្នុងឆ្នាំ២០១៥រួមមាន÷ ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិង សំណង់, និងក្រសួងយុត្តិធម៌។
- ក្រសួង ស្ថាប័នថ្មីចំនួន ១៥ និងមន្ទីរជំនាញរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៦ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកា-

កម្មវិធីនៅឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ រួមមាន៖ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា, និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកា និងលើការអនុវត្តថវិកា នឹងត្រូវផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្រសួងសាមី ចំណែកឯសិទ្ធិនៃការទទួលខុសត្រូវក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ទៅអង្គភាពថវិការបស់ក្រសួង ស្ថាប័ន។ ក្នុងន័យនេះ ក្រសួង ស្ថាប័នទាំងនេះកាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ក្នុងបរិការណ៍នេះ ដើម្បីជួយឱ្យក្រសួង ស្ថាប័នក្នុងការយកចិត្តទុកដាក់លើកកម្ពស់គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ឱ្យបានប្រសើរថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ដូចតទៅ៖

## ២. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានតួនាទីផ្តល់ជាទស្សនវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះបង្កើតបានជាលំហថវិការួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចកំណត់ទិសដៅការងាររយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។ នៅក្នុងន័យនេះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

### ២.១. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្អែកលើនិន្នាការសេដ្ឋកិច្ចឆ្នាំកន្លងទៅ ស្ថានភាពល្អប្រសើរនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល និងសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើកដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៥ ត្រូវបានព្យាករថាអាចសម្រេចបានក្នុងរង្វង់៧% ដូចតាមការគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ ចំពោះកំណើនសេដ្ឋកិច្ច

សម្រាប់ឆ្នាំ២០១៦វិញ តាមការព្យាករអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៣% វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ៩,៦% ដែលក្នុងនោះវិស័យវាយនភណ្ឌនឹងអាចសម្រេចបានប្រមាណ៨,៤% និងវិស័យសេវាកម្មគ្រោងថាអាចនឹងសម្រេចបានកំណើនប្រមាណតែ៦,៥% ប៉ុណ្ណោះ។

អតិផរណានៅឆ្នាំ២០១៥ តាមការព្យាករនឹងរក្សាបានក្នុងកម្រិត៣,៥%គឺដូចទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ហើយនឹងបន្តរក្សាកម្រិតថេរក្នុងរង្វង់៣,៥% ដដែលក្នុងឆ្នាំ២០១៦។ អត្រាប្តូរប្រាក់នៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានតម្លៃជាមធ្យម៤ ០៥០រៀល ក្នុង១ដុល្លារអាមេរិក ដូចគ្នានឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ តាមការព្យាករនៅឆ្នាំ២០១៦ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤០៥០រៀលក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

ឱនភាពគណនីចរន្តនៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានកម្រិត១០,៣%នៃផ.ស.ស គឺបានប្រសើរឡើងធៀបនឹងឆ្នាំ២០១៤ ដែលមានកម្រិត១១,២%នៃផ.ស.ស។ ទន្ទឹមនេះ តាមការព្យាករនៅឆ្នាំ២០១៦ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះទៀតមកត្រឹម៩,៧%នៃផ.ស.ស។ និន្នាការនៃការធ្លាក់ចុះឱនភាពគណនីចរន្ត ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលនិងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៥ ទុនបម្រុងនឹងមានទំហំ៥ ១៤៤លានដុល្លារអាមេរិក និងអាចកើនឡើងលើសពី៥ ៧៣៩លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដែលធានាបានប្រមាណជាង៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

**២.២ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

ដោយផ្អែកលើមូលដ្ឋាននៃ "យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨" គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៦-២០១៨ ត្រូវបានកំណត់គោលដៅសំខាន់ៗដូចតទៅ៖

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌និងប្រសិទ្ធភាពដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង បែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀលនៅឆ្នាំ២០១៨ ដោយផ្សាភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និង ការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិ

កំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមាន ការកែទម្រង់ប្រព័ន្ធកងកម្លាំងប្រដាប់អាវុធ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល
- បន្តជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
- បង្កើនប្រសិទ្ធភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ
- ធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព
- បន្តការជំរុញការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសបន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
- ពង្រឹង និងពង្រីកលំហាថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដោយចៃដន្យ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព ពង្រីកការទទួលបាន ភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានាបន្តការពារឱ្យបាននូវរាល់អធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅស្ថូចនាករហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោមនេះ÷

- ធានាកំណើនចំណូលចរន្តប្រចាំឆ្នាំបន្ថែម០,៥ពិន្ទុភាគរយនៃផ.ស.ស ដើម្បីឈានទៅសម្រេចឱ្យបាន១៧,៣៥% នៃផ.ស.ស នៅ២០១៦ ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៦,៤២% នៃផ.ស.ស និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិ គឺ០,៩៣% នៃផ.ស.ស។ ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន៨,៤២%នៃផ.ស.ស ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន៦,៥៩% នៃផ.ស.ស និង ចំណូលមិនមែនសារពើពន្ធនិងចំណូលពន្ធផ្សេងទៀត ត្រូវគ្រោងសម្រេចឱ្យបាន២,៣៥% នៃ

ផ.ស.ស។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវគ្រោងសម្រេចឱ្យបានស្មើនឹង ១៧,៥១% នៃផ.ស.ស។

០ ចំណាយសរុបនៅឆ្នាំ ២០១៦ នឹងកំណត់ក្នុងរង្វង់ ២១,២៨% នៃផ.ស.ស ក្នុងនោះចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិគ្រោង២០,៣៤% នៃផ.ស.ស និង ចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រោង ១,៥៦%នៃផ.ស.ស (ឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៦៣% នៃផ.ស.ស)។ ចំណាយចរន្តសរុបត្រូវគ្រោងក្នុងកម្រិត១៣,២៨%នៃផ.ស.ស ដែលចំណាយបន្ទុកបុគ្គលិកគ្រោងប្រមាណ៤៨,៤៨%នៃចំណាយចរន្តសរុប (គោលគឺមិនឱ្យលើស ៥០%) ឬស្មើប្រមាណ៦,៤៤% នៃផ.ស.ស ដោយផ្ដោតអាទិភាពលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្ដល់សេវាសាធារណៈ ទន្ទឹមនឹងការគិតគូរផងដែរចំពោះចំណាយមិនមែនបៀវត្សមួយចំនួន ពិសេសតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា ព្រមទាំងតម្រូវការចំណាយក្នុងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះដែរ ចំណាយមូលធនគ្រោងប្រមាណជា៨,០% នៃផ.ស.ស សម្រាប់ឆ្នាំ២០១៦។

០ ក្នុងគម្រោងក្របខណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៦ ត្រូវស្មើនឹង៤,០៧%នៃផ.ស.ស ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយត្រឹម ៣,៧៧%នៃផ.ស.ស។ ទំហំគុណភាពខាងលើគឺអាចធានាបាននូវចីរភាពថវិកា ដែលជាគន្លឹះរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផ្ដល់ភាពអនុគ្រោះដល់កំណើន ជាពិសេសបង្កើននូវលំហថវិកា។ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤-២០១៨ មានផ្ញើភ្ជាប់ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ការគ្រោងថវិកាឆ្នាំ២០១៦ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខណ្ឌនៃវិធានការ ដូចខាងក្រោម៖

**ផ្នែកចំណូល**

ជារួម ក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលទៅតាមគោលដៅកំណត់ខាងលើ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធនិងអាករបន្ថែមដល់ប្រជាជន និងធុរជននោះទេ ពោលគឺរាជរដ្ឋាភិបាលនឹងផ្ដោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយទាំងសម្រាប់រយៈពេលខ្លី និងមធ្យម ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ក្នុងនោះ រួមមានទាំងការកែសម្រួល និងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធ ពិសេសតាមរយៈការជំរុញអនុវត្តនូវ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។

**ក. ផ្នែកចំណូលគយ និងរដ្ឋាករ**

- បន្តពង្រឹងវិធានបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគយគ្រប់រូបភាព
- បន្តពង្រឹងការប្រកាសគយ តាមរយៈការពង្រឹងការគ្រប់គ្រងឯកសារនាំចេញ-នាំចូល និងការផ្ទៀង-ផ្ទាត់តម្លៃគិតពន្ធគយ ពិសេសចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន

- ពង្រឹងការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ
- ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ
- សិក្សា និង វាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូល ក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការដើម្បីធ្វើឱ្យប្រសើរឡើងនូវការកំណត់ពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល
- ជំរុញការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដាឱ្យអស់សក្តានុពល ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរជាតិតែមួយឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន
- បន្តពង្រឹងយន្តការសហប្រតិបត្តិការរវាងគយនិងវិស័យឯកជន
- វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយ ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប
- រៀបចំផែនការអភិវឌ្ឍស្ថាប័ន កែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ។

**២. ផ្នែកចំណូលពន្ធដារ**

- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូល
- បន្តពង្រឹង និងកែលម្អការផ្តល់សេវាដល់អ្នកជាប់ពន្ធ
- បន្តកែលម្អការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតការយកចិត្តទុកដាក់លើ÷
  - (១)- ការរៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ
  - (២)- អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល៣ខែជាប់គ្នា
  - (៣)- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមាបន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើងនូវការធ្វើសវនកម្មពន្ធដារ ទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដោយផ្តោតលើ÷
  - (១)- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដារ

រួមដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម

(២)- រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យ មុនពេលចុះសវនកម្មកន្លងមកសម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ

(៣)- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់និងបន្ថយបន្ទុកសវនកម្ម

(៤)- រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមានៈ ធនាគារ សំណង់ ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម។

- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- ជំរុញការបង្កើនចំណូលពីអាករលើតម្លៃបន្ថែម តាមរយៈ÷

(១)- រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត

(២)- បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

- ពង្រឹងការគ្រប់គ្រងរបបម៉ៅការ និងជំរុញការអនុវត្តរបបស្វ័យប្រកាស តាមរយៈ÷

(១)- រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំរួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែងដែលមានចំណូលខ្ពស់

(២)- រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំព្រួញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។

- ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- បន្តពង្រឹងកម្មវិធីផ្សព្វផ្សាយ និងការអប់រំពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ
- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស

- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីពន្ធដារ។

**គ.ផ្នែកចំណូលមិនមែនសារពើពន្ធ**

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយធ្វើសវនកម្មក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលប្រភេទនេះ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បន្តតាមដានការប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានវិធានការលើកទឹកចិត្ត សមស្របសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀត
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ រួចបង្កើតយន្តការតឹងទារបំណុលទាំងនោះ ដោយចាត់វិធានការព្រមាន ដកហូតអាជ្ញាបណ្ណ លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀត តាមការអនុញ្ញាតរបស់ច្បាប់ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល
- ពង្រឹងការគ្រប់គ្រងកាស៊ីណូ និងចំណូលពីកាស៊ីណូ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ
- ពង្រឹងការគ្រប់គ្រងធនធានប្រេងកាត និងរ៉ែ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ទន្ទឹមនឹងការសិក្សានិងធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណនិងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ ការបន្តរៀបចំទិន្នន័យនិងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យានិងអាជ្ញាបណ្ណដែលបានផ្តល់រួច
- រៀបចំ និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាពនូវការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងការប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា ការលក់សំបុត្រទស្សនាប្រាសាទរមណីយដ្ឋាន និងទីតាំងប្រវត្តិសាស្ត្រផ្សេងៗ
- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្នាក់នៅ ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ និងច្បាស់លាស់

- ពង្រឹងការបង់ចំណូលថវិកាពីថ្លៃសម្បទានដីសេដ្ឋកិច្ច និង ផលអនុផលព្រៃឈើពីព្រៃឈើពីសម្បទានិក តាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងការលក់និងការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច នីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច ការបង្កើនយន្តការនិងនីតិវិធីក្នុងការគ្រប់គ្រងនិងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើដីសម្បទានសេដ្ឋកិច្ច ភារីអគ្គិសនី ទំនប់ អាងស្រោចស្រព និងពីប្រភពផ្សេងៗទៀត
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើចំណាត់ថ្នាក់សណ្ឋាគារ និងការបង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ
- បន្តពង្រឹងការគ្រប់គ្រង និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈទាំងអស់ តាមរយៈត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ ធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ និងការធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុ ព្រមទាំង ពង្រឹងការអនុវត្តនូវកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ
- ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការសិក្សា និងរៀបចំឡើងវិញនូវក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការកែលម្អលក្ខន្តិកៈគតិយុត្តឱ្យស្របតាមការវិកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងដើម្បីផ្តល់លទ្ធភាពដល់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថាន ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍស្ថាប័នរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានស្រាប់
- លើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍ និង ជំរុញការរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍
- ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សាអំពីភាពប្រកួតប្រជែងរបស់កម្ពុជាពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗ នៅក្នុងតម្លៃនៃការធ្វើធុរកិច្ច អាជីវកម្ម និងពាណិជ្ជកម្មជារួមដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវា និងរង្វាន់លើកទឹកចិត្ត ផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ
- ពិនិត្យឡើងវិញ និងធ្វើកែប្រែជាយថាហេតុលើកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល

- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ និងការចុះបញ្ជីសារពើភ័ណ្ឌដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

<u>**ផ្នែកចំណាយ**</u>

- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សរ៍មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌ សង្គតិភាព ការធានាបាននិរន្តរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល
- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ពិសេសការពង្រឹងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាពីចំនួន១០ ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០១៥ ឱ្យឡើងដល់ ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេល ក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ទាំងចំណាយបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិក) ទាំងចំណាយមូលធន
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដោយបង្កើនការយកចិត្តទុកដាក់លើមុខចំណាយដែលបង្កើនផលិតភាព និងទ្រទ្រង់កំណើន
- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ចំណាយថវិកាលើមុខចំណាយទំនិញ និងសេវាមួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍និងអ៊ីនធើណេត ការកាត់បន្ថយទូរបេសកកម្មទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិតហើយមានតម្លៃខ្ពស់
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាល-វិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លីនិងអភិវឌ្ឍន៍ជនបទ ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យ។ល។
- បន្តការវិនិយោគលើការពង្រីក ការកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី ។ល។
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញផលិតឧស្សាហកម្មនិងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីគាំទ្រដល់ការជំរុញផលិតកម្មម្ហូបអាហារ
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយក្នុងគោលបំណងរក្សានិរន្តរភាពថវិកាឱ្យនៅត្រឹមកម្រិតសមរម្យមួយដែលមិនប៉ះពាល់និរន្តរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន "ឃ្លាំងថវិកា" សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការ

ចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់នានាទៀត
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ
- ពង្រឹងការគ្រប់គ្រង ឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត ក្នុងគោលបំណងផ្គូផ្គងធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីថ្មី។

## ៣. រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិកា

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានគូសរំលេចខាងលើបានកំណត់អំពីគោលដៅរួមនៃការប្រមូលចំណូល និងវិធានការចាំបាច់នានាដែលត្រូវអនុវត្តដើម្បីសម្រេចឱ្យបាននូវគោលដៅដែលបានដាក់ចេញនោះ ចំណែកខាងផ្នែកចំណាយវិញបានកំណត់អំពីគោលដៅរួមនៃចំណាយ និងបណ្តាអាទិភាពចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ដូចនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ ដើម្បីឈានទៅរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឱ្យបានល្អត្រឹមត្រូវ និងមានភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យក្រសួង ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នា រចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកា ត្រូវរៀបចំទៅតាមទម្រង់ដូចខាងក្រោម ៖

-ផ្នែកទី១: សេចក្តីផ្តើម:

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ត្រូវចាប់ផ្តើមដោយការរៀបរាប់អំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ និងការព្យាករសភាពការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងបញ្ហាប្រឈមផ្សេងៗ ដែលត្រូវដោះស្រាយជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០១៥ និងឆ្នាំខាងមុខ ។ បន្ទាប់មកត្រូវមានការរៀបរាប់អំពីវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តគោលនយោបាយដែលបាន

ដាក់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ សូមរៀបចំខ្លឹមសារនៃផ្នែកទី១នេះនៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

-ផ្នែកទី២: គោលបំណងគោលនយោបាយ:

គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេល មធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនអាចត្រូតពិនិត្យនិងវាយតម្លៃឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥របស់ខ្លួនបាន ដើម្បីកែសម្រួលគោលបំណងគោលនយោបាយឱ្យកាន់តែច្បាស់លាស់ និងសមស្របតាមវឌ្ឍនភាពជាក់ស្តែងនៃវិស័យរៀងៗខ្លួន។ សូមរៀបចំខ្លឹមសារនៃផ្នែកទី២នេះនៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

-ផ្នែកទី៣: កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព:

ការរៀបចំកម្មវិធី (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ត្រូវឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ហើយត្រូវបញ្ជាក់អំពីគោលបំណងនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតឈ្មោះកម្មវិធី រៀបរាប់និងពន្យល់អំពីគោលបំណងនៃកម្មវិធីដែលបានបង្កើត ឬ យុទ្ធសាស្ត្រអាទិភាព ព្រោះកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព គឺជាឧបករណ៍ដែលបានបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋានក្រោមឱវាទរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និង ចង្កោមសកម្មភាព (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬ ចង្កោមសកម្មភាពអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ព្រមទាំងលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២។

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ត្រូវមានខ្លឹមសារទូលាយ និងគ្របដណ្តប់បានទាំងស្រុងគ្រប់តួនាទី ភារកិច្ច និងបេសកកម្មរបស់ក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ទាំងរាល់គម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នត្រូវកំណត់អង្គភាពទទួលខុសត្រូវ និងអ្នកគ្រប់គ្រងនៅតាមរចនាសម្ព័ន្ធកម្មវិធី (ចំពោះក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (ចំពោះក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី)។ ទន្ទឹមនឹងនេះ ក្នុងក្របខណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង ស្ថាប័ននីមួយៗត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្តឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន។ មន្ទីរជំនាញរាជធានី ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី ខេត្ត គឺជាដៃរបស់ក្រសួងនៅតាមរាជធានី ខេត្ត ដែលមានភារកិច្ចរួមចំណែកអនុវត្តបណ្តាកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវណែនាំដល់មន្ទីរជំនាញរបស់ខ្លួននៅរាជធានី ខេត្ត អំពីអនុកម្មវិធីរមមួយនៅក្នុងកម្មវិធីមួយឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី ខេត្តរបស់ខ្លួនដឹងច្បាស់លាស់អំពីទីតាំងនៃអនុកម្មវិធីរមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពតែមួយគត់ក្រោមអនុកម្មវិធីរមមួយនៃកម្មវិធីមួយ លើកលែងតែក្រសួង ស្ថាប័នដែលមានតួនាទីនិងភារកិច្ចច្រើន ហើយការងារនោះភាគច្រើនអនុវត្តនៅថ្នាក់ក្រោមជាតិ ដូចជាក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាលជាដើម ដែលត្រូវមានអនុកម្មវិធីរមលើសពីមួយ ដែលជាសេវា ឬការងារគាំទ្រដល់កម្មវិធីលើសពីមួយ។ សូមបញ្ជាក់ផងដែរថា ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពមិនឱ្យលើសពី៥ឡើយ ប៉ុន្តែអាចមានអនុកម្មវិធីសមស្រប និងតាមការចាំបាច់។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងផងដែរទាំងធនធានថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនៃផ្នែកទី៣នេះ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកទី៣នេះ នៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

-ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករៈ

គោលបំណងគោលនយោបាយ និងកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់ និង ត្រូវកំណត់គោលដៅសូចនាករដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករ ឬហៅថាការជ្រើសរើសសូចនាករសម្រាប់ការវាស់វែង ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលក្នុងឆ្នាំគឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ នៅតាមគោលដៅដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់សមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលសម្រេចបានដោយការបូកបញ្ចូលគ្នានូវលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ក្រសួង ស្ថាប័ននីមួយៗ អាចកែសម្រួលសូចនាករនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ២០១៤ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ២០១៥ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។ កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករយ៉ាងច្រើនចំនួន៣ ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។ បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗនៅក្នុងរយៈពេលមធ្យមនិងវែង(លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុតគឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះចាំបាច់ត្រូវតែមានភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៤នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

-ផ្នែកទី៥: ការកំណត់ធនធាន:

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំង ថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៥នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។ ការកំណត់អំពីតម្រូវការធនធានដើម្បីអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំណត់ ជាពិសេសកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈកាលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្តែង និងមានសុក្រឹតភាពដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។

ការគ្រោងចំណូល គឺជាការព្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ដោយផ្អែកលើក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលចំណូលគ្រប់ប្រភេទទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនេះតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ប៉ុន្តែចំពោះ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្ត្រ រួមមានទាំងគោលនយោបាយ និងវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។ នៅក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវផ្អែកជាសំខាន់លើ÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត។

-ផ្នែកទី៦: សេចក្តីសន្និដ្ឋាន:

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និងការលើកទិសដៅ និងវិធានការដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និងមានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ និងដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ គឺជាដំណាក់កាលទី១នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង ស្ថាប័ននីមួយៗ មានលទ្ធភាពព្រាងផែនការថវិកាសម្រាប់អនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ដោយផ្សារភ្ជាប់គោលនយោបាយរបស់ក្រសួង ស្ថាប័ន ទៅនឹងថវិកា ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលបានដាក់ចេញរួចហើយ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផ្នែកមួយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការដ៏មានសារៈសំខាន់បំផុតសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ឱ្យបានសមស្រប ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវត្រួតពិនិត្យឡើងវិញនិងវាយតម្លៃលើការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥របស់ខ្លួន និងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ ហើយរៀបចំកែសម្រួលទៅតាមទម្រង់គំរូដូចបានភ្ជាប់ជាមួយសារាចរណែនាំនេះ។

*គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៦ ដែលមានវិសាលភាពគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលា*

គ្រប់គ្រាន់សម្រាប់ពិនិត្យ បូកសរុប និងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិគ្រោះនិងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួង ស្ថាប័នដែល មិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើប្រកបដោយគុណភាពទេ ត្រូវបានអនុញ្ញាត ឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើការវិភាជកញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់និសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាង ផ្នែកបច្ចេកទេសត្រូវទាក់ទងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋាន ថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
  "ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ